**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ[illegible]

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឱ្យទទួលបាននូវប្រសិទ្ធភាព និងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ រក្សាបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាព ព្រមទាំងធានាដល់ការថែរក្សាបរិស្ថាន វប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើរាល់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

**មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ** សំដៅដល់ទីតាំងសេវាកម្មទាំងឡាយដែលធ្វើអាជីវកម្មដើម្បីបម្រើឱ្យការសម្រាកលំហែនិងកម្សាន្តសម្រាប់មនុស្សពេញវ័យ។

**អាជីវកម្មរង្គសាល** សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រគំតន្ត្រីនិងច្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

**អាជីវកម្មឌីស្កូតែក** សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រើប្រាស់ឧបករណ៍ចាក់បទភ្លេងចម្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

**អាជីវកម្មខារ៉ាអូខេ** សំដៅដល់អាជីវកម្មនៅក្នុងបន្ទប់នៃអគារដោយប្រើប្រាស់ឧបករណ៍សំឡេង និងរូបភាព និងអក្សរសម្រាប់បម្រើភ្ញៀវច្រៀងកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

**អាជីវកម្មបៀរហ្គាឌិន** សំដៅដល់អាជីវកម្មដែលមានការប្រគំតន្ត្រីនិងការច្រៀងជូនភ្ញៀវ ដោយមានការបម្រើភេសជ្ជៈ និងម្ហូបអាហារគ្រប់ប្រភេទ។

**អនីតិជន** សំដៅដល់ជនដែលមានអាយុក្រោម១៨ឆ្នាំ លើកលែងតែអនីតិជននោះទទួលបានអត្តាធីនភាព។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ ._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ សម្រាប់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងការត្រួតពិនិត្យសកម្មភាពអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។

**មាត្រា៦ ._**

ការធ្វើប្រតិភូកម្មអំណាចក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមានសុពលភាពអប្បបរមារយៈពេល០១(មួយ)ឆ្នាំ គិតពីថ្ងៃចេញអាជ្ញាបណ្ណ។

**មាត្រា៧ ._**

លក្ខណវិនិច្ឆ័យក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍សម្រាប់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៣
## ការកំណត់ប្រភេទ ទីតាំង និងពេលវេលា

**មាត្រា៨ ._**

ប្រភេទអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យរួមមាន៖

- រង្គសាល
- ឌីស្កូតែក
- ខារ៉ាអូខេ
- បៀរហ្គាឌិន
- មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដទៃទៀត ដែលមានឧបនិស្ស័យបម្រើឱ្យវិស័យទេសចរណ៍។

**មាត្រា៩ ._**

ទីតាំងនៃមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកំណត់ទីតាំងធ្វើសកម្មភាពរបស់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវមានទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

១-មានចម្ងាយយ៉ាងតិច២០០(ពីររយ)ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន ទីតាំងសាសនា ប្រាង្គប្រាសាទ ទីតាំងបេតិកភណ្ឌវប្បធម៌។

២-មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន ទីតាំងសាសនា និងការរស់នៅរបស់ប្រជាពលរដ្ឋ។

៣- ធានារក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

**មាត្រា១០ ._**

អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មដូចខាងក្រោម៖

១- អាជីវកម្មវង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន ចាប់ដំណើរការអាជីវកម្មពីម៉ោង១៨:០០នាទីដល់ម៉ោង២៤:០០នាទី។

២- អាជីវកម្មខារ៉ាអូខេ ចាប់ដំណើរការអាជីវកម្មពីម៉ោង១០:០០នាទីព្រឹកដល់ម៉ោង២៤:០០នាទី។

ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០ត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## ការប្រតិបត្តិអាជីវកម្ម

**មាត្រា១១ ._**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១២ ._**

ប្រតិបត្តិករមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក. គោរពច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ខ. គោរពប្រពៃណី ទំនៀមទម្លាប់ និងមិនត្រូវចូលរួមឬធ្វើសកម្មភាពណាមួយដែលបំពានឬធ្វើឱ្យខូចប្រពៃណីនិងវប្បធម៌ជាតិ។

គ. មិនធ្វើអាជីវកម្មដែលបង្កឱ្យមានការប្រមូលផ្តុំក្មេងទំនើងនិងឱ្យសិស្សគេចសាលារៀន។

ឃ. ហាមអនីតិជននិងហាមយកអាវុធជាតិផ្ទុះចូលក្នុងទីតាំងធ្វើអាជីវកម្ម។

ង. រក្សាការពារសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវចូលកម្សាន្តនិងមិនធ្វើឱ្យមានសំឡេងរំខានដល់ប្រជាពលរដ្ឋរស់នៅជិតខាង។

ច. មិនត្រូវចូលរួម ឬមិនត្រូវធ្វើសកម្មភាពណាមួយដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗដូចជាការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរអាវុធ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពសម្ភារៈអាសអាភាស។

ឆ. ប្តឹងឬរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើស ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

ជ. ផ្តល់នូវព័ត៌មានពិតច្បាស់លាស់ដល់ភ្ញៀវចូលកម្សាន្តនិងទទួលខុសត្រូវផ្តល់សេវាកម្មល្អ ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិការពារសន្តិសុខនិងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្នុងទីកន្លែងអាជីវកម្មរបស់ខ្លួន។

ឈ. ត្រូវមានផែនការបណ្តុះបណ្តាល និងហ្វឹកហ្វឺនបុគ្គលិកបម្រើការងារទាំងពីរភេទ ដើម្បីលើកកម្ពស់សមត្ថភាពមុខជំនាញវិជ្ជាជីវៈ បដិសណ្ឋារកិច្ច និងការគ្រប់គ្រងទេសចរណ៍។

ញ. ចូលរួមផ្សព្វផ្សាយច្បាប់ផ្សេងៗដែលពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ រូបភាព និងសម្ភារៈអាសអាភាស។

ដ. ស្នើសហការជាមួយមន្ត្រីជំនាញ មន្ត្រីអធិការកិច្ចទេសចរណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មាន និងការធ្វើអធិការកិច្ច។

ឋ. ចូលរួមក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"។

**មាត្រា១៣ .–**

ប្រតិបត្តិករមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យណាម្នាក់ ដែលគិតថាបានទទួលរងគ្រោះអំពីការបដិសេធ ការព្យួរ ការលុប ការបញ្ចុះថ្នាក់ ឬការសម្រេចណាមួយ ដោយក្រសួងទេសចរណ៍ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចណាមួយដូចរៀបរាប់ខាងលើ។ បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្តីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ។

## ជំពូកទី៥
## ការហាមប្រាមអនីតិជន

**មាត្រា១៤ .–**

អនីតិជនមិនត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់ទីបរិវេណមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដូចជាឌីស្កូតែកនិងរង្គសាលឡើយ។

អនីតិជនអាចចូលទៅកម្សាន្តក្នុងបរិវេណមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដូចជាខារ៉ាអូខេនិងបៀហ្គាឌិនបាន ក្នុងករណីមានឪពុកម្តាយឬអាណាព្យាបាលទៅជាមួយ ដោយមានការធានាអះអាងច្បាស់លាស់។

**មាត្រា១៥ ._**

អ្នកគ្រប់គ្រងនិងម្ចាស់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវធ្វើបញ្ជីត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ ដើម្បីធានាឱ្យមានការប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន។

## ជំពូកទី៦
## អធិការកិច្ច

**មាត្រា១៦ ._**

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច ដោយចាត់តាំងមន្ត្រីជំនាញចុះត្រួតពិនិត្យសកម្មភាពមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ច ក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងករណីមានការប្រព្រឹត្តបទល្មើស ចាប់ពីបទមជ្ឈិមជាក់ស្តែងឡើងទៅ រដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនីតិវិធីច្បាប់ ដើម្បីផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្នជាបន្ទាន់និងត្រូវសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

## ជំពូកទី៧
## ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍

**មាត្រា១៧ ._**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចលុបចោល ព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន ក្នុងករណីដែលប្រតិបត្តិករទេសចរណ៍ផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណទេសចរណ៍។ ក្នុងករណីនេះ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ៣០(សាមសិប)ថ្ងៃជាមុនទៅកាន់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ និងត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់។

នៅក្នុងស្ថានភាពបន្ទាន់ដែលក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មទេសចរណ៍មួយ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរភ្លាមៗមកលើសុខភាព សុវត្ថិភាពឬសន្តិសុខនិងបង្កការរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋជិតខាង ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចលុបឬព្យួរអាជ្ញាបណ្ណទេសចរណ៍នោះ ជាបន្ទាន់ដោយបញ្ជាក់ហេតុផលច្បាស់លាស់។

**មាត្រា១៨ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ស្របតាមមាត្រា៥៥នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា១៩ .-**

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នឬការពិន័យអន្តរការណ៍មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍ដែលប្រព្រឹត្តល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា២០ .-**

បុគ្គលណាដែលធ្វើអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា២១ .-**

ប្រតិបត្តិករទេសចរណ៍ដែលប្រព្រឹត្តរំលោភលើកាតព្វកិច្ចដូចមានចែងក្នុងមាត្រា១២ និងមាត្រា១៥នៃអនុក្រឹត្យនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ស្របតាមមាត្រា៧០ និងមាត្រា៧១នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា២២ .-**

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា២៣ .-**

អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលចេញដោយក្រសួងទេសចរណ៍និងមន្ទីរទេសចរណ៍រាជធានី ខេត្តកន្លងមកដែលនៅមានសុពលភាព ត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យបន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងអនុក្រឹត្យនេះ។

លក្ខខណ្ឌទីតាំងដែលមានចែងនៅក្នុងមាត្រា៩ កថាខណ្ឌទី២ ចំណុចទី១នៃអនុក្រឹត្យនេះនឹងត្រូវយកមកអនុវត្តចំពោះតែការស្នើសុំអាជ្ញាបណ្ណថ្មីប៉ុណ្ណោះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ[illegible] ឆ្នាំ២០១៤[illegible]

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ